# ២-ភាសា បាលី សរសេរ ជាអក្សរខ្មែរ និង អក្សរ ឡាតាំង

ក្នុងភាសាបាលី មានស្រៈ៨តួៈ ចែកជា២ប្រភេទគឺៈ

<u>ក-ស្រៈនិស្ស័យ</u> (Voyelles simples)

I ◌ា ◌ិ ◌ី ◌ុ ◌ូ េ◌ ោ◌ ◌ំ(៤)

a ā i ī u ū e o ṃ

<u>ខ-ស្រៈពេញតួ</u> (Voyelles entières)

អ អា ឥ ឦ ឧ ឩ ឯ ឱ

a ā i ī u ū e o

ស្រៈ៨តួនេះ ចែកជា២ពួក គឺៈ

I ◌ិ ◌ុ មានសម្លេងខ្លី ហៅថា រស្សៈ <u>ឧទាហរណ៍ៈ</u> អគតិ

◌ា ◌ី ◌ូ េ◌ ោ◌ មានសម្លេងវែង ហៅថា ទីឃៈ <u>ឧទាហរណ៍ៈ</u> អាហារោ។

ស្រៈពេញតួ គេយកទៅប្រើជាតួអក្សរបង្កើតពាក្យបានដូចព្យញ្ជនៈដែរ។

----------------------------------------------------------------------

(៤)-និគ្គហិតសំរាប់ដាក់លើស្រៈ ៣តួ គឺ ।(អ) ◌ិ(អិ) ◌ុ(អុ)

កើតបានជាសម្លេង អាំង អឹង អុង ឧទាហរណ៍ :

កំ អានថា កាំង តំ អានថា តាំង

កឹ អានថា កឹង តឹ អានថា តឹង

កុំ អានថា កុង តុំ អានថា តុង។

## គ-ព្យញ្ជនៈ (Consonnes) ក្នុងភាសាបាលីមាន៣៣តួ:

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

k kh g gh ṅ c ch j jh ñ ṭ ṭh ḍ ḍh ṇ

ត្ត ថ្ថ ទ្ទ ធ្ធ ន្ន ប្ប ផ្ផ ព្ព ភ្ភ ម្ម

t th d dh n p ph b bh m

យ្យ ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ អ ។

y r l v s h ḷ a

គេចែកចេញជាវគ្គ ដូចនេះ ៖ ◌:

ក ខ គ ឃ ង = កវគ្គ

ច ឆ ជ ឈ ញ = ចវគ្គ

ដ ឋ ឌ ឍ ណ = ដវគ្គ

ត ថ ទ ធ ន = តវគ្គ

ប ផ ព ភ ម = បវគ្គ

យ រ ល វ ស ហ ឡ អ = សេសវគ្គ ។

## របៀបអានភាសាបាលី

*អក្សរបាលី គេមិនអាន ក ខ គ ឃ ង ដូចភាសាខ្មែរយើងទេ*

*ក អានថា កៈ ខ អានថា ខៈ គ អានថា គៈ ឃ អានថា ឃៈ ង អានថា ងៈ ........ រៀងរហូតដល់ចប់។ ប៉ុន្តែ អក្សរ ប មិនអានថា បៈ ទេ គេអានថា ប៉ៈ។*

***១- បើអក្សរវាយតួ*** *ត្រូវអានគ្រប់តួអក្សរ ព្រោះមិនមានតួណាប្រកបឲ្យតួណាទេ*

*ឧទាហរណ៍: សយនៈ ត្រូវអានថា សៈយៈនៈ អានថា សយនៈ មិនបានទេ ពហុល ត្រូវអានថា ពៈហុលៈ អានថា ពៈហុល មិនបានទេ។*

***២- អក្សរតម្រួតគ្នា ហើយអក្សរតម្រួតនោះនៅក្នុងវគ្គជាមួយគ្នា***

*អក្សរខាងលើគ្រាន់តែជាតួប្រកបអក្សរខាងដើម មិនអាចបញ្ចេញសម្លេងខ្លួនឯងបានទេ។ ចំណែកជើងអក្សរខាងក្រោម មានសិទ្ធិបញ្ចេញសម្លេង និងប្រើប្រាស់ស្រៈខាងលើនោះផង ឧទាហរណ៍: សក្ក ត្រូវអានថា សាក់ កៈ គឺអានសង្កត់ សាក់ ឲ្យធ្ងន់ នឹងអានថា សៈ កៈ មិនបានទេ ឬ នឹងអានថា សៈ កៈកៈ មិនបានទេ ព្រោះអក្សរលើគ្រាន់តែតួប្រកបប៉ុណ្ណោះ។ សច្ឆិ ត្រូវអានថា សាច់ ឆិ នឹងអានថា សៈ ឆិ ឬ សាច់ ចៈឆិ មិនបានទេ។*

***៣- អក្សរវគ្គដទៃតម្រួតលើអក្សរសេសវគ្គក្តី អក្សរសេសវគ្គតម្រួតលើអក្សរវគ្គដទៃក្តី***

*អក្សរខាងលើជាតួប្រកបអក្សរខាងដើមផង ជាតួគ្រវាត់ផ្សំជាមួយជើងខាងក្រោមផង ឧទាហរណ៍: សក្យ ត្រូវអានថា សាក់ ក្យៈ នឹងអានថា សៈ ក្យៈ ឬ សាក់ យៈ មិនបានទេ។ តត្រ ត្រូវអានថា តាត់ ត្រៈ នឹងអានថា តៈ ត្រៈ ឬ តាត់ រៈ មិនបានទេ។ កត្វា ត្រូវអានថា កាត់ ត្វា នឹងអានថា កៈ ត្វា ឬ កាត់ វ៉ា មិនបានទេ។ តណ្ហា ត្រូវអានថា តាន់ ណ្ហា នឹងអានថា តៈ ណ្ហា ឬ តាន់ ហា*

មិនបានទេ។ តស្មា ត្រូវអានថា តាស់ ស្មា នឹងអានថា តៈ ស្មា ឬ តាស់ ម៉ា មិនបានទេ។ កល្ប ត្រូវអានថា កាល់ ល្បៈ នឹងអានថា កៈ ល្បៈ ឬ កាល់ ប៉ៈ មិនបានទេ។

## ៤- បើអក្សរសេសវគ្គ តម្រួតគ្នាឯង

-តួនិងជើង ដូចគ្នា ដូចពាក្យថា អយ្យា តួលើគ្រាន់តែជាតួប្រកប មិនអាចបញ្ចេញសម្លេងបានទេ អយ្យា ត្រូវអានថា អ័យ យ៉ា នឹងអានថា អៈ យ៉ា ឬ អៈ យៈយ៉ា មិនបានទេ។

-អក្សរតម្រួតតួផ្សេងគ្នា(*) ដូចពាក្យ មឃ្ឃំ ត្រូវអានថា ម័យ ឃុំ នឹងអានថា មៈ ឃុំ ឬ ម័យ ហំ មិនបានទេ។ អស្វ ត្រូវអានថា អ័ស ស្វៈ នឹងអានថា អៈ ស្វៈ ឬ អ័ស វៈ មិនបានទេ។

---

(*)អក្សរខាងលើជាតួប្រកបអក្សរខាងដើមផង ជាតួគ្រវាត់ផ្សំជាមួយជើងខាងក្រោមផង។

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។